# ឋានសូត្រ



ដោយ

ភិក្ខុ និន-ភេន ឥន្ទប្បញ្ញោ

8 OCT. 1991

អំណោយពីលោក ខៀវ ឃុនសិរីឃ ដល់កុណារ័ត្ន
សម្រាប់ដាក់ទុកក្នុង eLibrary of Cambodia.

# ឋានសូត្រ



ដោយ

ភិក្ខុ ងិន-ភេន ឥន្ទប្បញ្ញោ

8 OCT 1991

# អារម្ភកថា

ឧបាសក យ៉ាង យ៉ីង ព្រមទាំងគ្រួសារ

ឧបាសក លឹម-ជិន ព្រមទាំងគ្រួសារ និង ញាតិមិត្រ មានសទ្ធាជ្រះថ្លា ជាអសង្ខារិក បានមកសុំអត្ថបទធម៌ យកទៅបោះពុម្ពចែកជាធម្មទាន ប្រារព្ធថ្ងៃ ៨ តុលា ដែលត្រូវនឹងថ្ងៃកំណើតរបស់ខ្ញុំព្រះករុណា អាត្មា ។

ខ្ញុំព្រះករុណា អាត្មា យល់ឃើញថា ឋានសូត្រ គ្រហស្ថ ឬបព្ជជិត ត្រូវតែសិក្សារៀនសូធ្យទាំងអស់គ្នា ទើបសរសេរអត្ថបទនេះ តាមទំនងដែលធ្លាប់ទេសនា ដើម្បីជូនចាត់ការបោះពុម្ព តាមសេចក្ដីជ្រះថ្លា ។

ខ្ញុំព្រះករុណា អាត្មា សង្ឃឹមថា លោកអ្នកអានទាំងឡាយនឹងបានផលប្រយោជន៍ខ្លះ ពីធម្មទាននេះ ជាពុំខាន ។

ថ្ងៃ ៨ តុលា ១៩៩១

ភិក្ខុ ឥន្ទបញ្ញោ ង៉ិន-ភេន

យថា វារិវហោ បូរោ   គច្ឆំ ន បរិវត្តតិ
ឯវមាយុ មនុស្សានំ   គច្ឆំ ន បរិវត្តតិ ។

ផ្លូវទឹកដ៏ពេញ កាលហូរទៅ រមែងមិនត្រឡប់ថយក្រោយវិញ យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ កាលកន្លងទៅ ក៏មិនត្រឡប់វិញ យ៉ាងនោះដែរ ។

យថាបិ តន្តេ វីតន្តេ   យំ យទេវោ បវុយ្ហតិ
អប្បកំ ហោតិ វេតព្វំ   ឯវំ មច្ចាន ជីវិតំ ។

តម្បាញដែលជាងត្បាញ   តម្បាញខាងមុខចេះតែតិចទៅ យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ   ក៏យ៉ាងនោះដែរ ។

បរិជិណ្ណមិទំ រូបំ   រោគនិឌ្ឍំ បភង្គុណំ
ភិជ្ជតិ បូតិសន្ទេហោ   មរណន្តំ ហិ ជីវិតំ ។

រូបនេះចាស់គ្រាំគ្រា ជាជម្រកនៃរោគ ជារបស់ពុកផុយ កាយស្អុយរមែងបែក   ព្រោះជីវិតមានសេចក្តីស្លាប់ជាទីបំផុត ។

# ឋានសូត្រ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មា នឹងសម្តែងធម៌ទេសនា ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ តាមគម្ពីរសុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ភាគ ៤៤ ទំព័រ ១៤៦ មានសេចក្តីដូចតទៅនេះ ÷

ឯកំ សមយំ ភគវា សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តព្រះជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ព្រះអង្គបានសម្តែងធម៌ទេសនា ដូចតទៅនេះ ÷

បញ្ចិមានិ ភិក្ខវេ ឋានានិ អភិណ្ហំ បច្ចវេក្ខិតព្វានិ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា ។ ម្នាលភិក្ខុទាំងឡាយ ឋានៈ «រឿង» ៥ ប្រការនេះ ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គប្បីពិចារណាឲ្យបានរឿយ ៗ ។ ឋានៈ ៥ ប្រការ តើដូចម្តេច ? ឋានៈ ៥ ប្រការគឺ ÷

១- ជរាធម្មោម្ហិ ជរំ អនតីតោ អាត្មាអញ មានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ ។

២- ព្យាធិធម្មោម្ហិ ព្យាធិំ អនតីតោ អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ ។

៣- មរណធម្មោម្ហិ មរណំ អនតីតោ អាត្មាអញ មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ ។

៤- សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អាត្មាអញ តែងមានសេចក្តីព្រាត់ប្រាស និរាស ចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ទាំងពួង ។

៥- កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ អាត្មាអញ មានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹង អាត្មាអញនឹងធ្វើនូវកម្មឯណា ទោះល្អក្តី អាក្រក់ក្តី នឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ ។

កិញ្ច ភិក្ខវេ អត្ថវសំ បដិច្ច .......... ម្នាលភិក្ខុទាំងឡាយ ការពិចារណារឿយ ៗ នូវឋានៈ ៥ ប្រការនេះ តើបានផលប្រយោជន៍អ្វីដែរ ?

អត្ថិ ភិក្ខវេ សត្តានំ ..... ម្នាលភិក្ខុទាំងឡាយ ការពិចារណា រឿយ ៗ នូវឋានៈ ៥ ប្រការនេះ រមែងបានផលប្រយោជន៍ ដូចតទៅនេះ ÷

១- ពួកសត្វ តែងមានសេចក្តីស្រវឹងក្នុងវ័យកម្លោះ ក្រមុំ « យោព្វនមទៈ » ដែលជាហេតុនាំឲ្យប្រព្រឹត្តទុច្ចរិតដោយកាយ វាចា ចិត្ត កាលបើបានពិចារណារឿយ ៗ ថា អាត្មាអញ មានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ ដូចនេះហើយ រមែងលះបង់នូវសេចក្តីស្រវឹងនោះទាំងស្រុងបាន ឬក៏ធ្វើឲ្យស្រាលស្តើងទៅបាន ។

២- ពួកសត្វ តែងមានសេចក្តីស្រវឹង ក្នុងភាពនៃខ្លួនជាអ្នកមិនមានរោគ « អារោគ្យមទៈ » ដែលជាហេតុនាំឲ្យប្រព្រឹត្តទុច្ចរិតដោយកាយ វាចា ចិត្ត កាលបើបានពិចារណារឿយ ៗ ថា អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ រមែងលះបង់នូវសេចក្តីស្រវឹងនោះទាំងស្រុងបាន ឬក៏ធ្វើឲ្យស្រាលស្តើងទៅបាន ។

៣- ពួកសត្វ តែងមានសេចក្តីស្រវឹងក្នុងជីវិត « ជីវិតមទៈ» ដែលជាហេតុនាំឲ្យប្រព្រឹត្តទុច្ចរិតដោយកាយ វាចា ចិត្ត កាលបើ

បានពិចារណារឿយ ៗ ថា អាត្មាអញ មានសេចក្ដីស្លាប់ជាធម្មតា មិនកន្លងសេចក្ដីស្លាប់ទៅបានឡើយ ដូចនេះហើយរមែងលះបង់នូវសេចក្ដីស្រវឹងនោះទាំងស្រុងបានឬក៏ធ្វើឲ្យស្រាលស្ដើងទៅបាន។

៤- ពួកសត្វ តែងមានសេចក្ដីត្រេកត្រអាល « ឆន្ទរាគៈ » ក្នុងសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ទាំងពួង ដែលជាហេតុនាំឲ្យប្រព្រឹត្តទុច្ចរិតដោយកាយ វាចា ចិត្ត កាលបើបានពិចារណារឿយៗថា អាត្មាអញ មានសេចក្ដីព្រាត់ប្រាស និរាសចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ទាំងពួង ដូចនេះហើយរមែងលះបង់ នូវសេចក្ដីត្រេកត្រអាល ក្នុងសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ទាំងស្រុងបាន ឬក៏ធ្វើឲ្យស្រាលស្ដើងទៅបាន ។

៥- ពួកសត្វ តែងប្រព្រឹត្តកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត កាលបើបានពិចារណារឿយ ៗ ថា អាត្មាអញ មានកម្មជារបស់ខ្លួន មានកម្មជាមរតក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹង អាត្មាអញ នឹងធ្វើនូវកម្មឯណា ទោះល្អក្ដី អាក្រក់ក្ដី នឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ ដូចនេះហើយរមែងលះបង់នូវទុច្ចរិតទាំងស្រុងបាន ឬក៏ធ្វើឲ្យស្រាលស្ដើងទៅបាន

ម្នាលភិក្ខុទាំងឡាយ អរិយសាវកនោះ រមែងពិចារណាឃើញថា មិនមែនអាត្មាអញតែម្នាក់ឯងទេ ដែលមានជរាជាធម្មតា មិនកន្លងជរាទៅបាន , មិនមែនអាត្មាអញតែម្នាក់ឯងទេ ដែលមានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន , មិនមែនអាត្មាអញតែម្នាក់ឯងទេ ដែលមានសេចក្ដីស្លាប់ជាធម្មតា មិនកន្លងសេចក្ដីស្លាប់ទៅបាន , មិនមែនអាត្មាអញតែម្នាក់ឯងទេ ដែលមានសេចក្ដីព្រាត់ប្រាស និរាស ចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ទាំងពួង , មិនមែនអាត្មាអញតែម្នាក់ឯងទេ ដែលមានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹង អាត្មាអញ នឹងធ្វើនូវកម្មឯណា ទោះល្អក្ដី អាក្រក់ក្ដី នឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ , សូម្បីពួកសត្វទាំងឡាយណា ដែលមានការរង្គាត់មក រង្គាត់ទៅច្យុតកើតឡើងអម្បាលម៉ាន សត្វទាំងឡាយនោះទាំងអស់ សុទ្ធតែមានជរាជាធម្មតា មិនកន្លងជរាទៅបាន , សុទ្ធតែមានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន , សុទ្ធតែមានសេចក្ដីស្លាបជាធម្មតា មិនកន្លងសេចក្ដីស្លាប់ទៅបាន , សុទ្ធតែមានសេចក្ដីព្រាត់ប្រាស និរាស ចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ទាំងពួង ,

សុទ្ធតែមានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹង និងធ្វើនូវកម្មឯណា ទោះល្អក្តី អាក្រក់ក្តី និងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ ដូច ៗ គ្នាទាំងអស់ ។

កាលអរិយសាវកនោះ ពិចារណារឿយ ៗ នូវឋានៈ ៥ ប្រការនេះហើយ មគ្គក៏កើតឡើងព្រម កាលចំរើននូវមគ្គនោះឲ្យច្រើនឡើង ៗ សញ្ញោជនៈ ក៏សាបសូន្យទៅ អនុស័យក្តិលេសក៏វិនាសទៅ ។

## អត្ថាធិប្បាយ

លោកអ្នកសប្បុរសទាំងឡាយ ព្រះធម្មទេសនានេះ មានសេចក្តីអធិប្បាយ ដូចតទៅនេះ ÷

១- មនុស្សយើងគ្រប់គ្នា ទោះបីស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី តែងមានសេចក្តីស្រវឹងនៅប្រចាំជានិច្ច មិនបាច់ផឹកស្រាទេក៏មានសេចក្តីស្រវឹងនៅស្រាប់ទៅហើយ បើផឹកស្រាថែមទៀត សេចក្តីស្រវឹងរិតតែមានកម្លាំងឡើងថែមទៀត បានជាព្រះលោកនាថជាម្ចាស់ត្រាស់ហាមការផឹកស្រា ។ តើយើងស្រវឹងអី ? យើងស្រវឹងក្នុងវ័យ ក្នុងភាពកម្លោះ ក្រមុំ «យោព្វនមទៈ»

យើងនៅក្មេងៈ ក្រមុំ យើងមិនទាន់ចាស់ជរាទេ យើងកុំគិតអី ច្រើន គិតតែសប្បាយទៅ ទាន់នៅក្មេង ធ្វើយ៉ាងម៉េចសប្បាយ ចេះតែធ្វើទៅ ខុសត្រូវកុំគិត ឲ្យតែយើងបានសប្បាយ ម៉្លោះហើយ ក៏ងាយនឹងធ្លាក់ខ្លួនទៅក្នុងអំពើទុច្ចរិតផ្សេងៗ កាយទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយកាយ លួច ប្លន់ កាប់ សម្លាប់ ខុសឆ្គងប្រពៃណី ប្តី ប្រពន្ធអ្នកដទៃ វចីទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយវាចា កុហក បញ្ឆោត ពោក ប្រាស់ មនោទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយចិត្ត គិតលោភលន់ចង់បានទ្រព្យធនអ្នកដទៃ គិតព្យាបាទ ប្រទូសរ៉ាយ បង្កសេចក្តីក្តៅក្រហាយទុក្ខលំបាកផ្សេង ៗ គិតរមិលគុណអ្នកមានឧបការៈដល់ខ្លួន មានមាតាបិតាជាដើម ។

បើស្ត្រី បុរស គ្រហស្ថ បព្វជិតណា បានពិចារណារឿយ ៗ ថា អាត្មាអញ មានជរាជាធម្មតា មិនអាចកន្លងជរាទៅបានឡើយ ពិតមែនតែអាត្មាអញ មិនទាន់មានធ្មេញបាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ ប៉ុន្តែ អាត្មាអញមានជរាហើយ ព្រោះជរាមាន ២ យ៉ាង គឺ : ១- បដិច្ឆន្នជរា ជរាបិទបាំង មិនប្រើបញ្ញាមិនយល់ទេ លុះតែប្រើបញ្ញាចក្ខុ ទើបអាចយល់បាន ទើបដឹងថាមានការប្រែប្រួលជានិច្ច មិននៅដដែលទេ ចេះតែទៅមុខជាដរាប ២- អប្បដិច្ឆន្នជរា

ជរាមិនបិទបាំង ប្រើតែមំសចក្ខុ ភ្នែកសាច់ក៏អាចយល់បាន សូម្បីតែកូនក្មេងក៏វាយល់ដែរ នឹ តាចាស់ជរាមកហើយ ខ្នងកោងសក់ស្កូវព្រោង ..... ។ កាលបើបានពិចារណារឿយ ៗ ដូចនេះហើយ ស្ត្រី បុរស គ្រហស្ថ បព្វជិតនោះ នឹងមានសតិសម្បជញ្ញៈភ្ញាក់រលឹកលះបង់នូវសេចក្តីស្រវឹងក្នុងវ័យ ក្នុងភាពកម្លោះ ក្រមុំទាំងស្រុងបាន ហើយខំសូធ្យរៀន ខំធ្វើការងារ ដោយសុចរិតស្លូតត្រង់ ធ្វើការងារបណ្តើរ សប្បាយបណ្តើរ បែបអ្នកមានសតិសម្បជញ្ញៈភ្ញាក់រលឹក ប្រសិនបើលះសេចក្តីស្រវឹងក្នុងភាពកម្លោះក្រមុំទាំងស្រុងមិនបានទេ យ៉ាងហោចណាស់ក៏ធ្វើឲ្យស្រាលស្តើងទៅបានដែរ គ្រាន់បើជាងអ្នកស្រវឹងស៊ប់ បានជាព្រះចមភពសម្តែងឲ្យពិចារណារឿយ ៗ ថា ជរាធម្មោម្ហិ ជរំ អនតីតោអាត្មាអញ មានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ ។

២- ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី តែងមានសេចក្តីស្រវឹងក្នុងភាពជាអ្នកមិនមានរោគ «អារោគ្យមទៈ» គឺស្រវឹងថាអាត្មាអញមានសុខភាពល្អ មិនមានរោគាព្យាធិ មិនឈឺថ្កាត់អ្វីទេម្ល៉ោះហើយមិននឹកនាដល់សេចក្តីល្អ មិនខំរកទ្រព្យសម្បត្តិ បើរកទ្រព្យសម្បត្តិបានមក ក៏ប្រើខ្ជះខ្ជាយ ជាមធ្យោបាយបម្រើសេចក្តី

សប្បាយខុសទំនង សប្បាយនឹងស្រី ស្រា ល្បែងពាលាផ្សេង ៗ គ្មានគិតសន្សំសំចៃ គ្មានគិតថ្ងៃអនាគត ដោយគិតខុសថា ថ្ងៃមុខ គង់រកទ្រព្យសម្បត្តិបានទៀត ព្រោះខ្លួនមានសុខភាពមាំមួនល្អ ណាស់ ប៉ុន្តែ សេចក្តីពិតអ្វី ៗ តែងប្រែប្រួលជានិច្ច រាងកាយក៏ ប្រែប្រួលជានិច្ចដែរ គ្មានអ្វីទៀងទាត់សោះទេ ថ្ងៃនេះរកទ្រព្យ សម្បត្តិបាន ថ្ងៃមុខរកមិនបាន ថ្ងៃហ្នឹងជា ថ្ងៃស្អែកឈឺ មួយថ្ងៃ កាត់ មួយថ្ងៃកោរ ព្រោះមនុស្សយើងមានរោគាព្យាធិជំងឺតម្កាត់ ច្រើនណាស់ ចក្ខុរោគា រោគក្នុងភ្នែក សោតរោគា រោគក្នុងត្រចៀក ។បេ។ គ្រាន់តែរោគក្នុងភ្នែកស្លាប់មិនរស់ ភ្នែកក្រហម អៀសុី កន្ទុយថ្លែនជាដើម ក្រៅពីជំងឺហើយ នៅមានតម្កាត់ទៀត ដូចជាការប៉ះទង្គិចបែកក្បាល បាក់ដៃ បាក់ជើង សុទ្ធតែជាឧបសគ្គ ដល់ការធ្វើសេចក្តីល្អ និង ការស្វែងរកទ្រព្យសម្បត្តិទាំងអស់ ។ បើស្ត្រី បុរស គ្រហស្ថ បព្វជិតណា បានពិចារណាដូចនេះ ស្ត្រី បុរស គ្រហស្ថ បព្វជិតនោះ នឹងមានសតិសម្បជញ្ញៈភ្ញាក់រលឹក អាចនឹងបន្ថោបង់នូវសេចក្តីស្រវឹង ក្នុងភាពជាអ្នកមិនមានរោគ ទាំងស្រុងបាន ឬយ៉ាងហោចណាស់ក៏ធ្វើឲ្យស្រាលស្តើងបាន បាន ជាព្រះទ្រង់ញាណប្រៀនប្រដៅកុំឲ្យប្រមាទ កុំឲ្យស្រវឹង ឲ្យខំប្រឹង

ពិចារណារឿយ ៗ ថា ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ ។

៣- សេចក្ដីស្លាប់ ជាភ័យមួយធំបំផុតរបស់សព្វសត្វ បើសេចក្ដីស្លាប់មកដល់ហើយ អ្វីដែលធ្លាប់បាន ធ្លាប់មាន ធ្លាប់សប្បាយរីករាយ គឺរាបចប់ រូបរាងកាយប្រើការមិនកើត យកជាគ្នាមិនបាន គេលែងរាប់អាន គេត្រូវតែយកចេញពីផ្ទះ បានជាមនុស្សយើងខ្លាចសេចក្ដីស្លាប់នេះណាស់។ បុគ្គលខ្លះចាស់ជិតស្លាប់ហើយ នៅតែមិនព្រមជឿងស្រវឹងក្នុងជីវិត «ជីវិតមទៈ» មិនងាយស្លាប់ទេ ពួកយើងអាយុវែង ៗ ណាស់ ហើយក៏ធ្លាក់ចុះក្នុងសេចក្ដីប្រមាទ ប្រហែសធ្វេស មិនប្រញាប់ប្រញាល់ធ្វើសេចក្ដីល្អ ចេះតែបង្វែបង្អង់បណ្ដោះបណ្ដែ ចាំអ៊ីចេះអ៊ីចុះបញ្ឆោតខ្លួនឯងមិនចេះចប់ លុះសេចក្ដីស្លាប់មកជិតដល់ តក់ស្លុតរន្ធត់ភ័យខាចខ៍អង្វរករថា ចាំធ្វើបុណ្យសិន អ្នកខ្លះថា បើមិនបានធ្វើបុណ្យក៏មិនអីដែរ ព្រោះយើងគ្មានធ្វើអ្វីអាក្រក់ទេ ប្រមាទពេញបន្ទុក លោភៈ ទោសៈ មោហៈ ពេញខ្លួននៅមិនយល់ថាបាបទៀត សូមជម្រាបថា ប៉ុណ្ណឹងល្មមគ្រប់គ្រាន់ហើយសម្រាប់ទុគ្គតិ ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិ បាដិកង្ខា បើចិត្តសៅហ្មងហើយ ពិតជាទៅទុគ្គតិ ។ បុគ្គលខ្លះយល់

ថា បើគិតដល់សេចក្តីស្លាប់ សេចក្តីស្លាប់មុខជាមកអីលូវហើយ ដូចនេះ កុំនឹកដល់វា បំភ្លេចវាចោលទៅ ។ សូមជម្រាបថា អ្វីទាំងអស់មិនមែនបានមកដោយសារនឹកទេ បើនឹកបាន នឹកបាន នឹកចង់ធ្វើសេដ្ឋី បានទៅជាសេដ្ឋីគ្រប់គ្នាហើយ អ្វីដែលគេបានសម្រេចនោះ ដោយសារគំនិតត្រូវផង ហើយគេធ្វើត្រូវល្អតាមគំនិតនោះផង ។ យើងនឹកពិចារណាដល់សេចក្តីស្លាប់ មិនមែនដើម្បីរកខ្សែមកចងកទេ ប៉ុន្តែដើម្បីភ្ញាក់រលឹកធ្វើការងារកសាងខ្លួនទាន់នៅមានឱកាសល្អ អ្នកស្រវឹងវង្វេងភាន់ច្រឡំ ខំបំភ្លេចសេចក្តីស្លាប់ កុំឲ្យវាមក ប៉ុន្តែវាមិនភ្លេចយើងទេ សូម្បី ១ វិនាទីវាក៏មិនភ្លេចយើងដែរ យើងទៅទីណា ក្នុងអាកាសក្តី ក្នុងរូងភ្នំក្តី ក្នុងសមុទ្រក្តី ឬទីណា ៗ ក្តី មិនផុតពីកណ្តាប់ដៃវាទេ វាតាមទាន់វារកឃើញទាំងអស់ ។ បុគ្គលខ្លះយល់ថា បើមុខជាស្លាប់ដដែលកុំខ្វល់ច្រើនពេក ខុសត្រូវកុំគិត ទុច្ចរិតក៏ដោយ ឲ្យតែបាន ឲ្យតែមាន ឲ្យតែសប្បាយ ចេះតែធ្វើទៅ យើងឈ្មោះថាបានកំរៃនៃជីវិតនេះហើយ ។ យើងសប្បាយបាន ៥០ ឆ្នាំ ៦០ ឆ្នាំ ស្លាប់ទៅវងកម្មរាប់កប្ប ម៉េចក៏មិនគិតផង គួរអនិច្ចា នេះហេតុតែស្រវឹងក្នុងជីវិត ។

ពិចារណារឿយ ៗ ថា ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ ។

៣- សេចក្ដីស្លាប់ ជាភ័យមួយធំបំផុតរបស់សព្វសត្វ បើសេចក្ដីស្លាប់មកដល់ហើយ អ្វីដែលធ្លាប់បាន ធ្លាប់មាន ធ្លាប់សប្បាយរីករាយ គឺរាំចប់ រូបរាងកាយប្រើការមិនកើត យកជាគ្នាមិនបាន គេលែងរាប់អាន គេត្រូវតែយកចេញពីផ្ទះ បានជាមនុស្សយើងខ្លាចសេចក្ដីស្លាប់នេះណាស់។ បុគ្គលខ្លះចាស់ជិតស្លាប់ហើយ នៅតែមិនព្រមឆ្លងស្រឡៃក្នុងជីវិត «ជីវិតមទៈ» មិនងាយស្លាប់ទេ ពូជយើងអាយុវែង ៗ ណាស់ ហើយក៏ធ្លាក់ចុះក្នុងសេចក្ដីប្រមាទ ប្រហែសធ្វេស មិនប្រញាប់ប្រញាល់ធ្វើសេចក្ដីល្អ ចេះតែបង្វែបង្អង់បណ្ដោះបណ្ដែ ចាំអ៊ីចេះអ៊ីចុះបញ្ឆោតខ្លួនឯងមិនចេះចប់ លុះសេចក្ដីស្លាប់មកជិតដល់ តក់ស្លុតរន្ធត់ភ័យខាចខ័អង្វរករថា ចាំធ្វើបុណ្យសិន អ្នកខ្លះថា បើមិនបានធ្វើបុណ្យក៏មិនអីដែរ ព្រោះយើងគ្មានធ្វើអ្វីអាក្រក់ទេ ប្រមាទពេញបន្ទុក លោភៈ ទោសៈ មោហៈ ពេញខ្លួននៅមិនយល់ថាបាបទៀត សូមជម្រាបថា ប៉ុណ្ណឹងល្មមគ្រប់គ្រាន់ហើយសម្រាប់ទុគ្គតិ ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិ បាដិកង្ខា បើចិត្តសៅហ្មងហើយ ពិតជាទៅទុគ្គតិ ។ បុគ្គលខ្លះយល់

ថា បើគិតដល់សេចក្ដីស្លាប់ សេចក្ដីស្លាប់មុខជាមកអីលូវហើយ ដូចនេះ កុំនឹកដល់វា បំភ្លេចវាចោលទៅ ។ សូមជម្រាបថា អ្វីទាំងអស់មិនមែនបានមកដោយសារនឹកទេ បើនឹកបាន នឹកបាន នឹកចង់ធ្វើសេដ្ឋី បានទៅជាសេដ្ឋីគ្រប់គ្នាហើយ អ្វីដែលគេបានសម្រេចនោះ ដោយសារគំនិតត្រូវផង ហើយគេធ្វើត្រូវល្អតាមគំនិតនោះផង ។ យើងនឹកពិចារណាដល់សេចក្ដីស្លាប់ មិនមែនដើម្បីរកខ្សែយកចងកទេ ប៉ុន្តែដើម្បីភ្ញាក់រលឹកធ្វើការងារកសាងខ្លួនទាន់នៅមានឱកាសល្អ អ្នកស្រវឹងវង្វេងភាន់ច្រឡំ ខំបំភ្លេចសេចក្ដីស្លាប់ កុំឲ្យវាមក ប៉ុន្តែវាមិនភ្លេចយើងទេ សូម្បី ១ វិនាទីវាក៏មិនភ្លេចយើងដែរ យើងទៅទីណា ក្នុងអាកាសក្ដី ក្នុងរូងភ្នំក្ដី ក្នុងសមុទ្រក្ដី ឬទីណា ៗ ក្ដី មិនផុតពីកណ្ដាប់ដៃវាទេ វាតាមទាន់វារកឃើញទាំងអស់ ។ បុគ្គលខ្លះយល់ថា បើមុខជាស្លាប់ដដែល កុំខ្វល់ច្រើនពេក ខុសត្រូវកុំគិត ទុច្ចរិតក៏ដោយ ឲ្យតែបាន ឲ្យតែមាន ឲ្យតែសប្បាយ ចេះតែធ្វើទៅ យើងឈ្មោះថាបានកំរៃនៃជីវិតនេះហើយ ។ យើងសប្បាយបាន ៥០ ឆ្នាំ ៦០ ឆ្នាំ ស្លាប់ទៅ រងកម្មរាប់កប្ប មេចក៏មិនគិតផង គួរអនិច្ចា នេះហេតុតែស្រវឹងក្នុងជីវិត ។

ព្រះសម្មាសម្ពុទ្ធសម្ដែងថា ជីវិតរបស់មនុស្សតិចណាស់ មិនយូរប៉ុន្មានទេ និងស្លាប់ហើយ ។ មនុស្សយើងប្រៀបដូចឆ្នាំងដីតូចក្ដី ធំក្ដី ដុតឆ្អិនក្ដី ដុតឆៅក្ដី សុទ្ធតែត្រូវបែកទៅវិញទាំងអស់យ៉ាងណាមិញ មនុស្សយើងតូចក្ដី ធំក្ដី ក្មេងក្ដី ចាស់ក្ដី សុទ្ធតែត្រូវស្លាប់ទៅវិញទាំងអស់ យ៉ាងនោះដែរ ។ យើងបានកើតមកជាមនុស្ស ទុកជាលាភមួយដ៏ប្រសើរណាស់ ព្រោះមានសត្វជាច្រើនទៀតដែលមិនមានភព្វបានមកកើតជាមនុស្សដូចយើង យើងមិនគួរយកជីវិតដ៏ថ្លៃថ្លានេះ ទៅធ្វើអំពើទុច្ចរិតទេ ព្រោះអំពើទុច្ចរិតនាំមកនូវសេចក្ដីទុក្ខក្ដៅក្រហាយ អស់កាលជាអង្វែង យើងគួរតែស្វះស្វែងកសាងសេចក្ដីល្អឲ្យបានច្រើន ព្រោះតម្លៃនៃជីវិតស្ថិតនៅលើសេចក្ដីល្អ រូប ជីវតិ មច្ចាន់ រូបរបស់សព្វសត្វ តែងតែបែកធ្លាយរលត់រលាយបាត់ទៅ ប៉ុន្តែ សេចក្ដីល្អតែងស្ថិតនៅជានិច្ច ជិតដាមតាមជាប់នឹងវិបាកវិញ្ញាណ រហូតដល់បានសម្រេចព្រះនិព្វាន ។ សេចក្ដីល្អនេះ ជាកត្តាសំខាន់កំណត់នូវសេចក្ដីសុខរបស់សព្វសត្វ ។ ហេតុនេះ កាលបើពិចារណាដល់សេចក្ដីស្លាប់ហើយ មិនគប្បីជាអ្នកប្រមាទ ប្រហែសធ្វេសឡើយ គប្បីជាអ្នកមានសតិសម្បជញ្ញៈភ្ញាក់រលឹកធ្វើប្រយោជន៍ឲ្យសម្រេចចុះ ។

ស្ត្រី បុរស គ្រហស្ថ បព្វជិត កាលបើបានពិចារណាតាមន័យ នេះហើយ អាចនឹងលះបង់នូវសេចក្ដីស្រឡាញ់ក្នុងជីវិតទាំងស្រុងបាន ឬយ៉ាងហោចណាស់ក៏ធ្វើឲ្យស្រាលស្ដើងទៅបានដែរ បានជាព្រះ ទ្រង់ញាណណែនាំឲ្យពិចារណារឿយ ៗ ថា មរណធម្មោម្ហិ មរណំ អនតីតោ អាត្មាអញ មានសេចក្ដីស្លាប់ជាធម្មតា មិនកន្លងសេចក្ដី ស្លាប់ទៅបានឡើយ ។

៤- មនុស្សយើងមិនមែនកើតមកទោលតែម្នាក់ឯង ត្រូវតែ មានមាតា បិតា បង ប្អូន បន្ទាប់មកត្រូវមានប្ដី ប្រពន្ធ កូន ចៅ បន្តពូជពង្សវង្សត្រកូល មិនតែប៉ុណ្ណោះ ត្រូវមានទ្រព្យសម្បត្តិ ផ្ទះ សម្បែង ប្រាក់ មាស ស្រូវ អង្ករ គោ ក្របី ដំរី សេះ ជាដើម បន្ថែមទៀត ។ មនុស្ស សត្វនិងទ្រព្យសម្បត្តិទាំងអស់នោះហើយ ដែលជួយសម្រួលឲ្យមនុស្សយើងមានជីវិតរស់នៅបានដោយស្រួល ដូចនេះ មនុស្សយើងតែងតែមានសេចក្ដីត្រេកត្រអាល ស្រឡាញ់ ជាប់ចិត្ត « ឆន្ទរាគៈ » ទៅលើរបស់អស់ទាំងនោះ រមែងមាន សេចក្ដីសម្គាល់ថា នោះជារបស់អញ ប្រាថ្នាឲ្យវាស្ថិតស្ថេរនៅជា មួយខ្លួនជាដរាប មិនចង់ឲ្យវាឃ្លាតព្រាត់ប្រាសនិរាសទៅណាទេ ។ បើរបស់អស់ទាំងនោះ វាព្រាត់ប្រាសឃ្លាតទៅដោយហេតុណាមួយ

មនុស្សយើងតែងមានសេចក្ដីទុក្ខសោកក្រៀមក្រំ ក្រេវក្រោធ ច្រឡោតខឹងរហូតដល់ធ្វើអំពើទុច្ចរិតផ្សេង ៗ ទៅក៏មាន នេះមកពីយើងមិនបានយល់ច្បាស់នូវសង្ខារធម៌ ។

ព្រះសម្មាសម្ពុទ្ធសម្ដែងថា សង្ខារធម៌ទាំងឡាយ ទោះបីមានវិញ្ញាណដូចមនុស្ស សត្វក្ដី ទោះបីមិនមានវិញ្ញាណដូចរបស់ប្រើប្រាស់ផ្សេង ៗ ជាដើមក្ដី សុទ្ធតែស្ថិតនៅក្រោមច្បាប់ធម្មជាតិ គឺមានលក្ខណៈជា អនិច្ចំ មិនទៀង ទុក្ខំ ជាទុក្ខទ្រាំនៅដដែលមិនបាន អនត្តា មិនមានខ្លឹមសារទាំងអស់ ឬនិយាយមួយបែបទៀតថា សង្ខារធម៌ទាំងឡាយ តែងមានជរា ការប្រែប្រួល ព្យាធិ ការឈឺចាប់ ទ្រុឌទ្រោម រង្គោះរង្គើ មរណៈ សេចក្ដីស្លាប់ បាក់បែកខូចខាត រលត់ទៅវិញជាធម្មតា មនុស្សយើងជាសង្ខារធម៌ដែរ ទ្រព្យសម្បត្តិរបស់យើងក៏ជាសង្ខារធម៌ដែរ ដូចនេះ វាត្រូវប្រព្រឹត្តទៅតាមច្បាប់ធម្មជាតិ ដូចសង្ខារឯទៀត ៗ ដែរ ។ សង្ខារធម៌ទាំងឡាយ រមែងកើតឡើងតាមហេតុតាមបច្ច័យរបស់វា បើអស់ហេតុអស់បច្ច័យហើយ វាត្រូវតែរលត់ទៅវិញជាធម្មតា ។ ឯការរលត់នោះទៀតសោត មិនបានប្រព្រឹត្តទៅដំណាលគ្នាជាមួយគ្នារហូតទៅទេ វាប្រព្រឹត្តទៅតាមហេតុតាមបច្ច័យរបស់វា ខ្លះទៅមុន

ខ្លះទៅក្រោយ នេះហើយដែលយើងហៅថាព្រាត់ប្រាសនិរាសចាក សត្វនិងសង្ខារ ។ សត្វក្នុងទីនេះ បានដល់អ្វីដែលមានជីវិត ឧទាហរណ៍ ប្ដី ប្រពន្ធ កូន ចៅ គោ ក្របី ជាដើម សង្ខារ បានដល់អ្វីដែលគ្មានជីវិត ឧទាហរណ៍ ផ្ទះសម្បែង តុ ទូ សំពត់អាវ ប្រាក់ មាស ជាដើម ។ បើយើងព្រាត់ប្រាសចាកសត្វនិងសង្ខារ មិនជាទីស្រឡាញ់មិនជាអីប៉ុន្មានទេ ប៉ុន្តែបើព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់វិញ យើងមានសេចក្ដីទុក្ខសោកក្រៀមក្រំ ច្រើនណាស់ បើស្រឡាញ់ច្រើន ទុក្ខច្រើន បើស្រឡាញ់តិច ទុក្ខតិច បើអត់ស្រឡាញ់សោះ គ្មានទុក្ខសោះ ។ ព្រះទ្រង់យសជាម្ចាស់ត្រាស់សម្ដែងឲ្យយើងសង្កេតមើលក្មេងលេងដីខ្សាច់ ធ្វើជាផ្ទះតូច ៗ ពេលវាកំពុងស្រឡាញ់ បើនរណាទៅធ្វើឲ្យខូចរបស់វា វាយំស្រែក វាក្រោធខឹង ពេលដែលវាឈប់ស្រឡាញ់ នរណាធ្វើអ្វីទៅលើផ្ទះតូច ៗ របស់វានោះ វាអត់មានកើតទុក្ខអ្វីទាំងអស់ បញ្ជាក់ថា ទុក្ខ កើតមកពីសេចក្ដីស្រឡាញ់ « ឆន្ទរាគៈ » ។

ស្ត្រី បុរស គ្រហស្ថ បព្វជិត កាលបើបានស្ដាប់ បានសិក្សា បានពិចារណាយល់ច្បាស់នូវសភាវធម៌ តាមអត្ថន័យដែលព្រះជិនស្រីសម្ដែងទុកនេះហើយ អាចនឹងលះបង់នូវឆន្ទរាគៈ សេចក្ដី

ត្រេកត្រអាល សេចក្ដីស្រឡាញ់ជាប់ចិត្តក្នុងសត្វនិងសង្ខារមាំង ស្រុងបាន ឬយ៉ាងហោចណាស់ក៏ធ្វើឲ្យស្រាលស្ដើងទៅបាន បានជាព្រះទ្រង់ញាណ ឲ្យពិចារណារឿយ ៗ ថា សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អាត្តាអញ្ញ តែងមានសេចក្ដីព្រាត់ប្រាស និរាស ចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ទាំងពួង ។

៥- មនុស្សយើងចង់បានសេចក្ដីសុខ សេចក្ដីចំរើនគ្រប់គ្នា ប៉ុន្តែមិនបានសម្រេចតាមបំណងប្រាថ្នានោះទាំងអស់ទេ ព្រោះអ្វី ? ព្រោះមិនស្គាល់ហេតុនៃសេចក្ដីសុខ ចំរើនឲ្យបានច្បាស់លាស់ បូកនិងសេចក្ដីលោភលន់ចង់បានចង់មានហួសប្រមាណ ដើរបំពារបំពាន គ្មានខ្មាសបាប ខ្លាចបាប ខ្វះហិរិឱត្តប្បៈ ធ្លាក់ខ្លួនទៅក្នុងផ្លូវខុស ផ្លូវទុច្ចរិតផ្សេង ៗ នេះឯងជាហេតុនាំឲ្យយើងមិនបានសេចក្ដីសុខចំរើន ហើយបែរជាជួបនិងសេចក្ដីទុក្ខលំបាកទៅវិញ ។

ព្រះសម្មាសម្ពុទ្ធសម្ដែងថា សេចក្ដីសុខចំរើន ទុក្ខលំបាក មិនមែនកើតឡើងដោយឥតហេតុទេ ហើយក៏មិនមែនកើតឡើងដោយហេតុខាងក្រៅ ព្រះឥន្ទ ព្រះព្រហ្មណា បណ្ដាលឲ្យទេ គឺពិត

ជាកើតឡើងដោយហេតុខាងក្នុងពោលគឺកម្មរបស់ខ្លួន ។ កម្ម មិនមែនអ្វីទេ គឺជាអំពើដែលយើងធ្វើដោយកាយ វាចា ចិត្ត អំពើដែលយើងធ្វើពីអតីតកាលក៏មាន ធ្វើក្នុងបច្ចុប្បន្ននេះក៏មាន អំពើទាំង ២ គឺ អតីតកម្ម បូកនឹងបច្ចុប្បន្នកម្ម បានមកជាផ្លែផ្កាដែលយើងកំពុងតែទទួលអីលូវនេះឯង ។ កម្មស្សកោម្ហិ យើងមានកម្មជារបស់ខ្លួន បានសេចក្ដីថា កម្មគឺអំពើដែលយើងធ្វើនេះ ជាទ្រព្យសម្បត្តិរបស់យើង មិនមែនរបស់នរណាទេ យើងជាម្ចាស់នៃកម្ម កម្មតែងដិតដាមតាមជាប់ជាមួយយើងជានិច្ច រាល់ភពរាល់ជាតិ មិនឃ្លាតឡើយ កម្មទាយាទោ យើងជាទាយាទ គឺជាអ្នកត្រូវទទួលនូវផលនៃកម្មនោះ និងគេចទៅណាមិនរួចទេ កម្មយោនិ យើងមានកម្មជាកំណើត. គឺកម្មជាអ្នកបង្កើតយើងឲ្យ បានល្អ អាក្រក់ សុខ ទុក្ខ គេស្រឡាញ់ គេស្អប់ មិនមែននៅ ស្ងៀម ៗ ស្រាប់តែគេស្អប់នោះទេ ហើយកម្មនេះ ជាអ្នកចាត់ចែងឲ្យយើងទៅកើតក្នុងភពថ្មីទៀត សមតាមអំពើដែលយើងធ្វើតប្រកែកបាន កម្មពន្ធុ យើងមានកម្មជាផៅពង្ស ជាញាតិសន្តាន ញាតិសន្តានខាងក្រៅជួយយើងបានម្ដងមួយកាល ចំណែកញាតិសន្តានខាងក្នុងពោលគឺកម្មនេះ តែងតែជួយយើងគ្រប់ពេលវេលាជានិច្ច

គ្មានញាតិសន្តានណាមួយអាចជួយយើងបានស្មើ និងកម្មរបស់ខ្លួន យើងនេះទេ អត្តា ហិ អត្តនោ នាថោ ខ្លួនជាទីពឹងរបស់ខ្លួន បើខ្លួនមិនកើតហើយ នរណានិងជួយដូចម្ដេចបាន សូមចាំទុកថា ញាតិអាក្រក់ ឬកម្មអាក្រក់ ជួយឲ្យទុក្ខលំបាក ញាតិល្អ ឬ កម្មល្អ ជួយឲ្យសុខចំរើន កម្មប្បដិសរណោ យើងមានកម្មជាជំរក ជំរក យើងមាំ ឬមិនមាំ ទ្រេតទៅរកទុក្ខ ឬ សុខ អាស្រ័យលើកម្ម មានកម្មជាគ្រឿងការពារ បើយើងធ្វើល្អ ការពារមិនឲ្យទទួលផល អាក្រក់ មានកម្មជាគ្រឿងរាំងរា បើយើងធ្វើអាក្រក់រាំងរាមិនឲ្យ ទទួលផលល្អ មានកម្មជាទីពឹង យើងពឹងមាតាបិតា ក៏លោកប្រាប់ ឲ្យធ្វើការងារ ពឹងព្រះពុទ្ធ ក៏ព្រះអង្គប្រៀនប្រដៅឲ្យធ្វើកុសលកម្ម រួមសេចក្ដីត្រូវពឹងទៅលើកម្មដដែល ដូចនេះ យើងធ្វើកម្មឯណា ល្អក្ដី អាក្រក់ក្ដី ត្រូវជាអ្នកទទួលនូវផលនៃកម្មនោះទាំងអស់ ។

ស្ត្រី បុរស គ្រហស្ថ បព្វជិតណា កាលបើបានពិចារណានូវ គោលធម៌ដ៏សំខាន់ ដែលព្រះអនន្តញាណបានសម្ដែងទុកដូចនេះ ហើយ ស្ត្រី បុរស គ្រហស្ថ បព្វជិតនោះ អាចនិងលះបង់នូវទុច្ចរិត ដោយកាយ វាចា ចិត្ត ទាំងស្រុងបាន ឬយ៉ាងហោចណាស់ក៏ធ្វើឲ្យ ស្រាលស្តើងទៅបាន បានជាព្រះទ្រង់ញាណឲ្យពិចារណារឿយៗ ថា

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ម៉ាន ជាន្នី**

តុលា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដារី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ីស និងលោកម្តាយ ឱិន សៅខុន

សូមអរគុណ

ខ្ទៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

## មានលក់ដុំ និង លក់រាយ

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "បណ្ណាគារត្រៃរតន៍"

#136E0 វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ: 012 706 581

097 905 00 55

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ៗ